ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.[illegible]សហវ..[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែតុលា ឆ្នាំ ២០១៧

ជម្រាបជូន

លោកប្រធានមន្ទីរសុខាភិបាលខេត្តស្វាយរៀង

កម្មវត្ថុ ករណីសំណើសុំពិនិត្យសម្រេចជ្រើសរើសក្រុមហ៊ុន និងប្រគល់កិច្ចសន្យាជូន ក្រុមហ៊ុន ឧត្តម ពន្លឺជ័យ ខនស្រ្តាក់សិន ដើម្បីទទួលការងារជួសជុលអគារមន្ទីរសុខាភិបាលខេត្ត បន្ទប់ទឹកមន្ទីរពេទ្យខេត្ត អគារចត្តាឡីស័ក និងអគារមណ្ឌលសុខភាពមេសថ្ងក ជូនមន្ទីរសុខាភិបាលខេត្តស្វាយរៀង ឆ្នាំ២០១៧ ។

យោង - លិខិតលេខ ០០៣ ល.ខ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧ របស់មន្ទីរសុខាភិបាលខេត្តស្វាយរៀង
- កំណត់ហេតុបើកឯកសារដេញថ្លៃលេខ ០១០ កបលក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ និងកំណត់ហេតុវាយតម្លៃ និងប្រគល់កិច្ចសន្យាលេខ ០១០ វកល ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧ របស់ក្រុមលទ្ធកម្មនៃមន្ទីរសុខាភិបាលខេត្តស្វាយរៀង
- ទិដ្ឋាការធានាចំណាយលេខ ០០០៩៩៨ ហ.វ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧ របស់អភិបាលហិរញ្ញវត្ថុខេត្តស្វាយរៀង ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់មន្ទីរសុខាភិបាលខេត្តស្វាយរៀង ក្នុងការប្រគល់កិច្ចសន្យាជូន **ក្រុមហ៊ុន ឧត្តម ពន្លឺជ័យ ខនស្រ្តាក់សិន** ដើម្បីអនុវត្តការងារជួសជុលអគារមន្ទីរសុខាភិបាលខេត្ត បន្ទប់ទឹកមន្ទីរពេទ្យខេត្ត អគារចត្តាឡីស័ក និងអគារមណ្ឌលសុខភាពមេសថ្ងក ជូនមន្ទីរសុខាភិបាលខេត្តស្វាយរៀង ក្នុងតម្លៃទឹកប្រាក់សរុបចំនួន **១ ៤៦១ ៣០០ ០០០**រៀល (មួយប៊ីលាន បួនរយហុកសិបមួយលាន បីរយពាន់រៀលគត់) ជាតម្លៃកិច្ចសន្យា ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធានជ្រាប និងមានវិធានការអនុវត្តបន្តឱ្យបានសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមលោកប្រធាន ទទួលនូវការរាប់អានអំពីខ្ញុំ

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
រដ្ឋលេខាធិការ

ជុំ និរិទ្ធ

ចម្លងជូន ៖
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តស្វាយរៀង
- សាខាពន្ធដារខេត្តស្វាយរៀង
- រតនាគារខេត្តស្វាយរៀង
- ក្រុមហ៊ុន ឧត្តម ពន្លឺជ័យ ខនស្រ្តាក់សិន
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 666 Fax : 855-23-427 798